# សេចក្តីថ្លែងការព័ត៌មាន
# មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បញ្ចប់បេសកកម្មមកកម្ពុជា

ភ្នំពេញ ថ្ងៃទី 7 ខែ វិច្ឆិកា ឆ្នាំ 2008

បេសកកម្មមួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មកពីទីក្រុងវ៉ាស៊ីនតោន ឌីស៊ី បានធ្វើទស្សនៈកិច្ចនៅកម្ពុជា ពីថ្ងៃទី 23 ខែ តុលា ដល់ថ្ងៃទី 07 ខែ វិច្ឆិកា ឆ្នាំ 2008 ដើម្បីធ្វើកិច្ចពិគ្រោះយោបល់មាត្រាទី IV[១] (Article IV Consultation)។ ក្នុងឱកាសបំពេញទស្សនកិច្ច បេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបានពិនិត្យមើលការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្មីៗ ជួបពិភាក្សាជាមួយរដ្ឋមន្ត្រីនិងមន្ត្រីជាន់ខ្ពស់នានា នៃរាជរដ្ឋាភិបាលកម្ពុជា អំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធ របស់រាជរដ្ឋាភិបាល។ បេសកកម្មក៏បានជួបជាមួយអ្នកតំណាងនានាមកពី សហគមពាណិជ្ជកម្ម ដៃគូអភិវឌ្ឍន៍របស់កម្ពុជា វិទ្យាស្ថានស្រាវជ្រាវ សហជីពការងារ រួមទាំងអង្គការក្រៅរដ្ឋាភិបាលផងដែរ ។

បន្ទាប់ពីការអនុវត្តបានដ៏ខ្លាំងក្លាក្នុងកំឡុងប៉ុន្មានឆ្នាំ សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ជួបនូវភាពប្រឈមចំពោះមុខមួយចំនួនក្នុងឆ្នាំ 2008។ បន្ទាប់ពីការចាប់ផ្តើមដ៏ខ្លាំងក្លា ចលករនៃកំណើនបានថមថយក្នុងឆ្នាំ ហើយនៅពេលថ្មីៗនេះទៀត សេដ្ឋកិច្ចចាប់ផ្តើមទទួលរងឥទ្ធិពលអវិជ្ជមានពីភាពតានតឹងផ្នែកហិរញ្ញវត្ថុរបស់ពិភពលោក។ ការនាំចេញនៃផលិតផលសំលៀកបំពាក់ និង ចំនួននៃទេសចរណ៏មកដល់ កំពុងបង្អង់ល្បឿន ដែលឆ្លុះបញ្ចាំងពីភាពស្រុតចុះយ៉ាងលឿននៃសេដ្ឋកិច្ចរបស់ដៃគូរពាណិជ្ជកម្មចំបងៗ និងបង្ហាញពីការលំបាកចំពោះភាពប្រកួតប្រជែងរបស់កម្ពុជា ដោយសារតែការឡើងថ្លៃយ៉ាងក្រាស់ក្រែលទាំងប្រាក់រៀលនិងប្រាក់ដុល្លាពេលថ្មីៗនេះ គួបផ្សំនឹងអតិផរណាក្នុងស្រុកខ្ពស់។ សកម្មភាពសំណង់ និងការវិនិយោគបរទេសកំពុងបន្ថយល្បឿនពីកំរិតខ្ពស់ មួយផ្នែកដោយសារតែលក្ខខ័ណ្ឌខ្សត់ជាងមុននៃសាច់ប្រាក់ងាយស្រួល (Liquidity)។ កត្តាទាំងអស់នេះត្រូវរំពឹងថា នឹងបង្កអោយមានភាពទន់ខ្សោយនៃកំណើន គឺបានត្រឹមតែ 6½ ភាគរយក្នុងឆ្នាំ 2008 ហើយនឹង មានភាពបង្អន់ល្បឿនបន្ថែមទៀតក្នុងឆ្នាំ 2009 ដែលកំណើនអាចបានតែ 4¾ ភាគរយ ។

---

[១] ក្រោមកិច្ចពិគ្រោះយោបល់មាត្រាទី IV បុគ្គលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិអនុវត្តការអង្កេត និង ការវិភាគលើការអភិវឌ្ឍន៍ និង នយោបាយសេដ្ឋកិច្ច របស់ប្រទេសជាសមាជិកនានា សំរាប់ការពិភាក្សាដោយគណៈកម្មការប្រតិបត្តិ។ កិច្ចពិគ្រោះយោបល់មាត្រា ទី IV ចុងក្រោយបំផុតធ្វើនៅឆ្នាំ 2007។

អតិផរណាបានកើនយ៉ាងលឿនក្នុងពាក់កណ្តាលទីមួយនៃឆ្នាំ 2008 ឆ្លុះបញ្ចាំងអំពី ថ្លៃម្ហូបអាហារនិងប្រេងដែលខ្ពស់ជាងមុន ភាពទន់ខ្សោយនៃប្រាក់ដុល្លាអាមេរិក និងសំពាធនៃតំរូវការក្នុងប្រទេស។ ទោះបីជាយ៉ាងនេះក្តី ការប្រែក្រឡាស់នៃកត្តាទាំងនេះនាពាក់កណ្តាលទីពីរនៃឆ្នាំ 2008 នាំមុខដោយថ្លៃប្រេងដែលទាបជាងមុន គួរតែបង្កអោយមានការថយចុះនៃអតិផរណាទូទៅ ពីកំរិតដែលខ្ពស់បំផុតគឺ 26 ភាគរយក្នុងខែ ឧសភា ធៀបនឹងឆ្នាំមុន មកត្រឹម 15½ ភាគរយ នៅចុងឆ្នាំ។ ជាមួយនឹងសំពាធសេចក្តីត្រូវការក្នុងស្រុកដែលគ្រោងថានឹងមានភាពថមថយ អតិផរណាគួរបន្តនិន្នាការថយចុះក្នុងឆ្នាំក្រោយ។

ឱនភាពគណនីចរន្តក្រៅប្រទេស (រួមទាំងការផ្ទេរផ្លូវការ) ត្រូវបានប៉ាន់ប្រមាណថាបានកើនឡើងយ៉ាងគ្រាស់ក្រែលក្នុងឆ្នាំ 2008 គឺប្រមាណ 12¼ ភាគរយនៃផលទុនជាតិសរុប ឆ្លុះបញ្ចាំងនូវការប៉ះទង្គិចនៃការឡើងថ្លៃប្រេង និងការនាំចូលដ៏ខ្លាំងក្លាជំរុញដោយតំរូវការក្នុងស្រុក។ ដោយលំហូរចូលដ៏ខ្លាំងក្លានៃមូលធននៅពាក់កណ្តាលទីមួយនៃឆ្នាំ 2008 ទុនបំរុងអន្តរជាតិដុលបានកើន ដល់ 2.2 ពាន់លានដុល្លា នៅបំណាច់ខែ កញ្ញា ឆ្នាំ 2008។ សំរាប់ឆ្នាំ 2009 ឱនភាពគណនីចរន្តក្រៅប្រទេសត្រូវរំពឹងថា និងថយចុះដល់ 8 ភាគរយនៃផលទុនជាតិសរុប ដោយសារតែឥទ្ធិពលនៃថ្លៃប្រេងដែលទាបជាងមុននិងការថយចុះនៃតំរូវការ មានលើសពីការប៉ះពាល់ដោយការនាំចេញសំលៀកបំពាក់និងវិស័យទេសចរណ៍ដែលខ្សោយជាងមុន។

បេសកកម្មបានកោតសសើររដ្ឋអំណាច ក្នុងការថែរក្សាលំនឹងនៃការអនុវត្តថវិកា ជាពិសេសក្នុងកំឡុងពេលបោះឆ្នោត។ ចំណូលរបស់រដ្ឋាភិបាលបានបន្តកើនឡើងក្នុងឆ្នាំ 2008 ហើយត្រូវបានគ្រោងថា នឹងកើនដល់ 12½ ភាគរយនៃផលទុនជាតិសរុប ដោយសារការកែលំអនៃរដ្ឋបាលពន្ធដារនៅតែបន្ត។ ចំណាយត្រូវបានរក្សានៅក្នុងកំរិតប្រហាក់ប្រហែលនឹងគោលដៅថវិកា នាំមកនូវការថយចុះនៃឱនភាពថវិកាទូទៅរបស់រដ្ឋាភិបាល (ដោយមិនរួមបញ្ចូលជំនួយអត់សំណង) ពី 3 ភាគរយនៃផលទុនជាតិសរុប ក្នុងឆ្នាំ 2007 មកប្រហែល 2 ភាគរយ ក្នុងឆ្នាំ 2008។

កិច្ចពិភាក្សានានា អំពីគោលនយោបាយសារពើពន្ធ បានផ្តោតទៅលើការឆ្លើយតបយ៉ាងសមស្រប ចំពោះការគ្រោងទុកនៃការថយចុះសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ បេសកកម្មបានចាត់ទុកថា ភាពបន្ធូរបន្ថយដោយប្រុងប្រយ័ត្នទប់ទល់នឹងខួបសេដ្ឋកិច្ច នៃគោលនយោបាយសារពើរពន្ធ គួរតែត្រូវធ្វើទៅបាននៅឆ្នាំ 2009 ដោយការប្រមើលមើលថាកំណើននឹងខ្សោយហើយគ្រោងថាមានការថយចុះនៃសំពាធអតិផរណា។ បេសកកម្មបានផ្តល់អនុសាសន៍ថា ឱនភាពថវិកាទូទៅរបស់រដ្ឋាភិបាលអាចអនុញ្ញាតអោយកើនដល់ប្រមាណ 3¼ ភាគរយនៃផលទុនជាតិសរុប។ ដើម្បីគាំពារចំណូល បេសកកម្មបានជំរុញរដ្ឋាភិបាលអោយជៀសវាងនូវភាពធ្លាក់ចុះនៃភាពជឿនលឿនក្នុងផ្នែករដ្ឋបាលចំណូល។ បេសកកម្មបានផ្តល់យោបល់ថា អាទិភាពត្រូវផ្តល់ដល់ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងការចំណាយសង្គមកិច្ចជួយដល់ជនក្រីក្រ ដើម្បីបញ្ចៀសការប៉ះពាល់នៃការបន្ថយល្បឿននៃកំណើន។

លក្ខខ័ណ្ឌរូបិយវត្ថុ បានទទួលនូវភាពបន្ធូរបន្ថយច្រើនលើសលប់នៅពាក់កណ្តាលទីមួយនៃឆ្នាំ 2008 រួមចំណែកធ្វើអោយមានកំណើនយ៉ាងហួសប្រមាណនៃឥណទានផ្តល់អោយវិស័យឯកជន ដែលកំណើននេះកើនដល់កំពូលគឺ 103 ភាគរយ ក្នុងខែ មិថុនា ប្រៀបនឹងឆ្នាំមុន ហើយបណ្តាលអោយមានសំពាធអតិផរណាក្នុងស្រុក។ ធនាគារជាតិនៃកម្ពុជាបានឆ្លើយតបយ៉ាងសមស្រប ដោយបង្កើនទ្វេដងនៃទុនបំរុងកាតព្វកិច្ចចំពោះប្រាក់បញ្ញើរធនាគារជារូបិយប័ណ្ណដល់ 16 ភាគរយ ក្នុងខែ ឧសភា។ បន្ទាប់ពីពេលនោះ កំណើនឥណទានបានថយចុះ ប៉ុន្តែនៅតែខ្ពស់លើសពី 80 ភាគរយ ប្រៀបធៀបឆ្នាំមុន។ ប្រសិនបើកំណើនឥណទាន និងសំពាធអតិផរណាបន្តថយចុះ ការបន្ធូរបន្ថយខ្លះៗនៃគោលនយោបាយរូបិយវត្ថុ អាចឃើញថាត្រឹមត្រូវ។

ដោយទទួលស្គាល់ពីភាពប្រឈមនានា បង្ហាញអោយឃើញដោយលក្ខខ័ណ្ឌហិរញ្ញវត្ថុពិភពលោកថ្មីៗនេះ រដ្ឋអំណាចបានបញ្ជាក់ម្តងហើយម្តងទៀតអំពីការសំរេចចិត្តរបស់ខ្លួន ដើម្បីបន្តពង្រឹងការគ្រប់គ្រងធនាគារ ក្នុងពេលជាមួយគ្នានោះកែលំអរបបនិយតភាព (Regulatory Regime)។ បេសកកម្មបានសង្កត់ធ្ងន់ថា វិធានការតឹងរ៉ឹងចំពោះការអនុវត្តបទបញ្ញាតិប្រុងប្រយ័ត្ន (Prudential Regulations) នឹងជួយគាំពារប្រព័ន្ធធនាគារនៃប្រទេសកម្ពុជា។